ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ: 628 PEAC.អក

រាជធានីភ្នំពេញ, ថ្ងៃទី 10 ខែ ឧសភា ឆ្នាំ 2016

## សេចក្តីជូនដំណឹង
## ស្តីពី

ការចូលរួមដេញថ្លៃ ឈ្នួលពលកម្មសាងសង់ ពង្រីកបណ្តាញអាកាសនិងកប់ដី MV ថ្មី នៅភូមិគោកបេង (១) សង្កាត់គោចក ក្រុងសៀមរាប, និងពង្រីកបណ្តាញអាកាស និងកប់ដី LV ថ្មី នៅភូមិតាកុយ ឃុំបល្ល័ង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ជូនអគ្គិសនីសៀមរាប (កញ្ចប់ 11-2)

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការ ពង្រីកបណ្តាញអាកាសនិងកប់ដី MV ថ្មី នៅភូមិគោកបេង (១) សង្កាត់គោចក ក្រុងសៀមរាប, និងពង្រីកបណ្តាញអាកាស និងកប់ដី LV ថ្មី នៅភូមិតាកុយ ឃុំបល្ល័ង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ជូនអគ្គិសនីសៀមរាប (កញ្ចប់ 11-2) ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី 10 ខែ ឧសភា ឆ្នាំ 2016 តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website : www.edc.com.kh ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី 09 ខែ មិថុនា ឆ្នាំ 2016 វេលាម៉ោង 14:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង 15:30 ថ្ងៃទី 09 ខែ មិថុនា ឆ្នាំ 2016 ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ